UNFPA United Nations Population Fund

# របាយការណ៍បូកសរុបសិក្ខាសាលាស្ដីពី

## “ការចូលរួមគាំទ្រស្ត្រីបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធទទួលបានរបបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល”



## នៅសណ្ឋាគារភ្នំពេញ

### ថ្ងៃអង្គារ ២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
### ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ នៅសណ្ឋាគារភ្នំពេញ សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ដោយបានការឧបត្ថម្ភថវិកាពីមូលនិធិទីភ្នាក់ងារអង្គការសហប្រជាជាតិដើម្បីប្រជាជនប្រចាំប្រទេសកម្ពុជាបានរៀបចំសិក្ខាសាលា “ការចូលរួមគាំទ្រស្ត្រីបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធទទួលបានរបបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍។

## ១. គោលបំណង

- បង្ហាញលទ្ធផលនៃការអង្កេតសិក្សាមុនការអនុវត្តគម្រោង លទ្ធផលនៃការអនុវត្តគម្រោងរយៈពេល៦ខែកន្លងមក បញ្ហាប្រឈម ដើម្បីស្វែងរកដំណោះស្រាយ និងអនុសាសន៍ក្នុងការធ្វើឱ្យកាន់តែប្រសើរក្នុងដំណើរការផ្តល់និងការប្រើប្រាស់ប្រព័ន្ធគាំពារសង្គមដល់ស្ត្រីធ្វើការនៅក្នុងសេវាកម្សាន្ត។
- ដើម្បីពង្រឹងកិច្ចសហការជាមួយស្ថាប័ន ដៃគូពាក់ព័ន្ធ ក្នុងការជម្រុញនិងធ្វើឱ្យកាន់តែមានភាពងាយស្រួលដល់ស្ត្រីជាក្រុមគោលដៅក្នុងការទទួលបានប័ណ្ណមូលនិធិសមធម៌សុខាភិបាលនិងការប្រើប្រាស់សេវានៅតាមទីតាំងផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាពនិងប្រសិទ្ធិភាព។

## ២. លទ្ធផលរំពឹងទុក

- អ្នកចូលរួមទាំងអស់ នឹងយល់ដឹងកាន់តែច្បាស់ពីស្ថានភាពបច្ចុប្បន្ន និងតម្រូវការចាំបាច់ទាក់ទងនឹងសុខភាពបន្តពូជនិងសិទ្ធិ និងការសម្របសម្រួលស្ត្រីធ្វើការក្នុងសេវាកម្សាន្តឱ្យទទួលបានប័ណ្ណមូលនិធិសមធម៌សុខាភិបាល
- ទទួលបានការគាំទ្រពីដៃគូរសហការ និងអ្នកពាក់ព័ន្ធ
- យន្តការ និតិវិធីក្នុងការផ្តល់ និងប្រើប្រាស់ប័ណ្ណមូលនិធិសមធម៌សុខាភិបាលនឹងមានភាពងាយស្រួល

## ៣. អ្នកចូលរួម សរុប ១៨៣រូប

- គណៈអធិបតីចំនួន**១៦រូប** (អញ្ជើញមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងផែនការ ក្រសួងសង្គមកិច្ច ក្រសួងកិច្ចការនារី ក្រសួងទេសចរណ៍ ក្រសួងធម្មការនិងសាសនា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក អភិបាលរងរាជធានីភ្នំពេញ និងថ្នាក់ដឹកនាំសមាគមនារី)
- មកពីមណ្ឌលសុខភាពចំនួន**១៣រូប**
- សង្កាត់ចំនួន**៦រូប**
- ស្រុកប្រតិបត្តិ**៨រូប**
- ក្រសួង-ស្ថាប័ន ពាក់ព័ន្ធចំនួន**១៤រូប**
- តំណាងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ចំនួន**១៧រូប**
- តំណាងគ្រឹះស្ថានកម្សាន្តចំនួន**១៤រូប**
- ស្ត្រីធ្វើការតាមសេវាកម្សាន្តចំនួន**៤២រូប**
- បុគ្គលិកគម្រោងរបស់សមាគមនារីចំនួន**៤១រូប** (អ្នកអប់រំផ្ទាល់ ១៧រូប បុគ្គលិកអភិបាល និងមន្ត្រីស្នាក់ការកណ្តាល **២៤រូប**)
- អ្នកសារព័ត៌មានចំនួន**១២រូប**

## ៤. ដំណើរការនៃសិក្ខាសាលា

លោកជំទាវ **ម្សៀច សុធារី** អគ្គលេខាធិការសមាគមនារីបានមានមតិស្វាគមន៍ចំពោះសិក្ខាសាលា និងបានបញ្ជាក់ថាសមាគមនារី បាននិងកំពុងអនុវត្តគម្រោងកាត់បន្ថយការរីករាលដាលនៃជំងឺអេដស៍ជាមួយស្ត្រីបម្រើការក្នុងសេវាកម្សាន្តនៅក្នុងរាជធានីភ្នំពេញ ខេត្តព្រៃវែង កណ្តាល និងព្រះសីហនុ ដោយបានទទួលមូលនិធិពីអង្គការខាណា និងគម្រោងសុខភាពបន្តពូជនិងសិទ្ធិ ជាមួយស្ត្រីបម្រើការងារក្នុងសេវាកម្សាន្តក្នុងរាជធានីភ្នំពេញដោយបានទទួលថវិកាពីមូលនិធិអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា បានសហការយ៉ាងជិតស្និតជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ម្ចាស់សេវា និងក្រុមស្ត្រីដើម្បីរៀបចំបញ្ជីឈ្មោះ បញ្ជូនទៅក្រសួងការងារ ឬឃុំ/សង្កាត់ដើម្បីស្នើសុំប័ណ្ណមូលនិធិសមធម៌សុខាភិបាល និងបានជួយសម្របសម្រួលនៅក្នុងការសម្ភាសន៍។ល។ មកដល់បច្ចុប្បន្នក្នុងខេត្តទាំង៤ មានស្ត្រីចំនួន ១,០៦៣នាក់ បានចុះឈ្មោះស្នើសុំប័ណ្ណក្រីក្រ ក្នុងនោះ៥៥៧នាក់មានឯកសារត្រឹមត្រូវតាមលក្ខខណ្ឌ និងទទួលបានប័ណ្ណក្រីក្រចំនួន១២៦នាក់ក្នុងនោះភ្នំពេញទទួលបាន២៧នាក់ និងប័ណ្ណមូលនិធិសមធម៌សុខាភិបាលចំនួន៦១៨នាក់ ក្នុងនោះភ្នំពេញ៥៨០នាក់។

ថ្លែងក្នុងអង្គសិក្ខាសាលា លោកស្រី **សាន់ដ្រា ប៊ឺនក្លាច** (Sandra Bernklau) នាយិកាទីភ្នាក់ងារអង្គការសហប្រជាជាតិដើម្បីប្រជាជនប្រចាំកម្ពុជា (UNFPA) បានសម្តែងការកោតសរសើរ និងដឹងគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ចំពោះការដឹកនាំនិងការប្តេជ្ញាចិត្ត ក្នុងការធានាឱ្យមានបរិយាប័ន្នដល់ប្រជាជនដែលប្រឈមមុខខ្ពស់ ទៅក្នុងគោលនយោបាយនិងកម្មវិធីគាំពារសង្គមរបស់ប្រទេស។ ស្ត្រីអាចទទួលបានសេវាសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសុខភាពមាតា ប្រកបដោយគុណភាព រួមទាំងផែនការគ្រួសារ។ លោកស្រីបានបន្តទៀតថា UNFPA មានកិត្តិយសក្នុងភាពជាដៃគូជាមួយសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងការអភិវឌ្ឍន៍ (CWPD) ដើម្បីគាំទ្រដល់ស្ត្រីធ្វើការក្នុងសេវាកម្សាន្តឱ្យអាចចុះឈ្មោះ និងទទួលបានបេឡាជាតិរបបសន្តិសុខសង្គម និងប័ណ្ណមូលនិធិសមធម៌សុខាភិបាល ហើយ UNFPA ជំរុញឱ្យភាគីពាក់ព័ន្ធទាំងអស់ពិចារណាដំណើរការចុះឈ្មោះជាបន្តសម្រាប់ស្ត្រីបម្រើការងារនៅសេវាកម្សាន្តដែលមានហានិភ័យខ្ពស់នៅក្នុងប្រព័ន្ធ ប.ស.ស. ។ លោកស្រី បានស្នើឱ្យបន្តសុពលភាពនៃប័ណ្ណមូលនិធិសមធម៌សុខាភិបាល (ម.ស.ស) រហូតដល់ទៅ៣ឆ្នាំ ដែលមានរយៈពេលវែងជាងប័ណ្ណ ម.ស.ស បច្ចុប្បន្នដែលមានសុពលភាព១ឆ្នាំ វានឹងផ្តល់ស្ថេរភាពកាន់តែប្រសើរឡើង ដល់ក្រុមមានហានិភ័យខ្ពស់ និងងាយរងគ្រោះខ្លាំងដូចជាស្ត្រីធ្វើការក្នុងសេវាកម្សាន្ត។ លោកស្រី បានស្នើឱ្យភាគីពាក់ព័ន្ធទាំងអស់ពិចារណាលើដំណើរការចុះឈ្មោះជាបន្តសម្រាប់កម្មករក្រៅប្រព័ន្ធ និងក្រុមមានហានិភ័យខ្ពស់ទៅក្នុងប្រព័ន្ធគាំពារសង្គម ដែលអាចនាំឱ្យការចុះឈ្មោះមានការកើនឡើងជាលំដាប់។ លោកស្រី បានលើកឡើងថា ការលើកកម្ពស់សេវាថែទាំសុខភាពដែលផ្តោតលើសិទ្ធិមនុស្ស និងស្ត្រីដោយស្មើភាព ពិតជាមានសារៈសំខាន់ ដែលគោលបំណងរួមរបស់យើង គួរតែកាត់បន្ថយ ប្រសិនបើមិនទាន់អាចលុបបំបាត់ទាំងស្រុង នូវការមាក់ងាយ និងការរើសអើងដល់ស្ត្រីធ្វើការក្នុងសេវាកម្សាន្ត ក៏ដូចជាប្រជាជនងាយរងគ្រោះផ្សេងទៀត ជួបប្រទះទាំងនៅកន្លែងផ្តល់សេវាថែទាំសុខភាព និងសង្គមទាំងមូល។

**យន្តការ និងនិតិវិធីរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តរបបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌**

អង្គសិក្ខាសាលាបានស្តាប់បទបង្ហាញ៖

- ឯកឧត្តម **ហួត ហៃ** អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ បានលើកឡើងអំពីការយកចិត្តទុកដាក់របស់សាលារាជធានីភ្នំពេញ ក្រោមការដឹកនាំរបស់ ឯកឧត្តម **ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ស្តីពីការតម្រង់ទិស ដល់មន្ទីរទេសចរណ៍ មន្ទីរផែនការ មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវរួមសហការគ្នាផ្ទៀងផ្ទាត់ ចុះស្រង់ទិន្នន័យ និងសុំប័ណ្ណមូលនិធិសមធម៌សុខាភិបាល (ម.ស.ស) ជូនដល់បុគ្គលិកបម្រើសេវាកម្សាន្តវិស័យទេសចរណ៍, ស្នើឱ្យរដ្ឋបាលខណ្ឌទាំង១៤ និងអង្គភាពពាក់ព័ន្ធផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ម្ចាស់អាជីវកម្មសេវាកម្សាន្តទេសចរណ៍ ស្តីពីអត្ថប្រយោជន៍ ម.ស.ស ដោយឥតគិតថ្លៃស្របតាមគោលការណ៍ស្ម័គ្រចិត្ត, ស្នើឱ្យមន្ទីរសុខាភិបាលរាជធានីភ្នំពេញត្រូវយកចិត្តទុក្ខដាក់ផ្តល់សេវាពិនិត្យសុខភាព តាមស្តង់ដារបច្ចេកទេស ប្រកបដោយវិជ្ជាជីវៈ និងមានក្រមសីលធម៌, គ្រប់ស្ថាប័នរួមសហការគ្នាដោះស្រាយបញ្ហាប្រឈម សំណូមពរចាំបាច់របស់នារីពីការប្រើប្រាស់សេវាមូលនិធិសមធម៌សុខាភិបាល និងជម្រុញការប្រើប្រាស់សេវានេះឱ្យបានពេញលេញ និងរៀបចំពិធីចែកប័ណ្ណជូនដល់បងប្អូនបម្រើការសេវាកម្សាន្តវិស័យទេសចរណ៍។

- លោក **ឡើន ឆានី** ប្រធាននាយកដ្ឋានគាំពារសង្គមកម្ពុជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្តោតទៅលើប្រព័ន្ធសន្តិសុខសង្គម តួនាទីក្រុមប្រឹក្សាជាតិគាំពារសង្គម អំពី ប.ស.ស និង ម.ស.ស

- លោក **ហុង សុខហៀម** ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តោតទៅវិសាលភាពផ្តល់កិច្ចគាំពារសង្គម ដល់ស្ត្រីបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ច ក្រៅប្រព័ន្ធទទួលបានរបបថៃទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល។ ឆ្លើយតបនឹងការស្នើសុំឱ្យមានសុពលភាពរយៈពេលវែងនៃប័ណ្ណមូលនិធិសមធម៌សុខាភិបាល (ម.ស.ស) និង ប័ណ្ណក្រីក្រ លោកបានយល់ព្រមនាំយកសំណើនេះ ក្នុងការពិភាក្សាបន្ថែមជាមួយបេឡាជាតិសន្តិសុខសង្គម។

- លោក **ឌិត្យ ច័ន្ទត្រស្នា** - អ្នកសម្របសម្រួលគម្រោងសុខភាពបន្តពូជនិងសិទ្ធិ បានបង្ហាញនូវលទ្ធផលនៃការអង្កេតសិក្សាមុនអនុវត្តគម្រោង។

- លោក **ឆន អាន** ប្រធានកម្មវិធីសមាគមនារីបានធ្វើបទបង្ហាញនូវលទ្ធផលនៃការអនុវត្តគម្រោង និងដំណើរការនៃការសម្របសម្រួលស្ត្រីធ្វើការក្នុងសេវាកម្សាន្តទៅទទួលប័ណ្ណ មូលនិធិសមធម៌សុខាភិបាល។

**បញ្ហាប្រឈមដែលបានលើកឡើងដោយស្ត្រីធ្វើការក្នុងសេវាកម្សាន្ត និងតាមរយៈការសង្កេតនៅទីតាំងៈ**

- ស្ត្រីមួយចំនួនមិនមានឯកសារគ្រប់គ្រាន់ក្នុងការសម្ភាសន៍ដូចជា អត្តសញ្ញាណប័ណ្ណ និងប័ណ្ណគ្រួសារ
- សមត្ថកិច្ចមិនបានចេញលិខិតបញ្ជាក់ឱ្យស្ត្រីដែលមិនមែនជាពលរដ្ឋរស់នៅក្នុងខេត្ត

- ក្នុងថ្ងៃយុទ្ធនាការធ្វើប័ណ្ណក្រីក្រ ស្ត្រីមួយចំនួនមិនបានចូលរួមដោយមូលហេតុៈ ត្រឡប់ទៅស្រុកកំណើត ស្ត្រីខ្លះកំពុងជាប់បម្រើភ្ញៀវ ខ្លះទៀតផ្លាស់ទីលំនៅ
- មិនមានថវិកាសម្រាប់ធ្វើដំណើរមកកន្លែងសម្ភាសន៍

**៥. ដំណើរការនៃសិក្ខាសាលាអនុសាសន៍ និងជំហ៊ានបន្ទាប់**

**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍** បានមានប្រសាសន៍ថា សិក្ខាសាលានេះពិតជាមានសារៈសំខាន់ណាស់ គឺសមស្របទៅនឹងគោលបំណង និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដែលបាននឹងកំពុងយកចិត្តទុកដាក់ក្នុងការជួយដល់ប្រជាពលរដ្ឋទាំងអស់ដែលជួបការលំបាកនិងមិនទុកនរណាម្នាក់ចោលដោយមិនបានដោះស្រាយឡើយ រួមទាំងស្ត្រីដែលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** បានថ្លែងអំណរគុណដល់ក្រសួង/ស្ថាប័ននិងដៃគូពាក់ព័ន្ធទាំងអស់ដែលបានអនុវត្តដោយជោគជ័យនូវអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន** និងសេចក្តីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាល និងសេចក្តីប្រកាសអន្តរក្រសួងស្តីពីការផ្តល់របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងផ្តល់អនុសាសន៍អាទិភាពមួយចំនួនដល់សិក្ខាសាលាៈ

១)ក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ទាំងអស់ត្រូវចូលរួមគាំទ្រស្ត្រីបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធទទួលបានរបបថែទាំសុខភាព រួមបញ្ចូលទាំងសេវាសុខភាពបន្តពូជនិងសិទ្ធិ និងសេវាមធ្យោបាយពន្យារកំណើត តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលនិងទទួលបានសេវាសុខភាព ដោយសមភាពនិងសមធម៌ ដោយគ្មានការរើសអើង តាមសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល។

២)បន្តអនុវត្តឱ្យមានប្រសិទ្ធភាពនិងឆាប់រហ័សនូវការផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល និងប័ណ្ណក្រីក្រដល់ជនបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

៣)បង្កើនកិច្ចសហការឱ្យកាន់តែជិតស្និទ្ធរវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អាជ្ញាធរមូលដ្ឋាន អង្គការសមាគម និងអ្នកព័ន្ធទាំងអស់ពិសេសម្ចាស់គ្រឹះស្ថាននិងស្ត្រីបម្រើការក្នុងសេវាកម្សាន្ត។

៤)ចែករំលែកព័ត៌មាន ការលំបាក បញ្ហាប្រឈមជាប្រចាំដើម្បីរួមគ្នាដោះស្រាយបានទាន់ពេលវេលា។

៥)សូមម្ចាស់មូលនិធិនិងដៃគូអភិវឌ្ឍន៍ទាំងអស់មេត្តាបន្តផ្តល់ថវិកាដល់អង្គការ សមាគមក្នុងស្រុក ដែលកំពុងអនុវត្តគម្រោងសុខភាពដូចជាគម្រោងកាត់បន្ថយការរីករាលដាលនៃជំងឺអេដស៍ សុខភាពបន្តពូជ សិទ្ធនិងជម្រើសក្នុងការទទួលបាននូវសេវាសុខភាពក្នុងចំណោមស្ត្រីបម្រើការក្នុងសេវាកំសាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធដើម្បីរួមចំណែកក្នុងការអនុវត្តឱ្យបានជោគជ័យនូវទិសដៅដើម្បីឆ្ពោះទៅសម្រេចបានគោលដៅកាត់បន្ថយអេដស៍ ៩៥, ៩៥, ៩៥ នៅឆ្នាំ២០២៥ខាងមុខ។

៦)ចូលរួមសកម្មភាពជម្រុញការផ្តល់ប័ណ្ណក្រីក្រ និងប័ណ្ណមូលនិធិសមធម៌សុខាភិបាលដល់ស្ត្រីបម្រើក្នុងសេវាកម្សាន្ត ឱ្យបានកាន់តែច្រើននិងឆាប់រហ័ស។

មានមតិបូកសរុប និងប្រកាសបិទសិក្ខាសាលាលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍បានបញ្ជាក់ថា រាជរដ្ឋាភិបាលតែងតែមានការយកចិត្តទុកដាក់ខ្ពស់ដោយដាក់តម្កល់សិទ្ធិ និងអាយុជីវិតរបស់ប្រជាពលរដ្ឋជាធំឆ្លើយតបតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដើម្បីធានាថា "មិនទុកចោលនរណាម្នាក់"។ ទោះជាយ៉ាងណាការខិតខំប្រឹងប្រែងនាពេលកន្លងមកនៅតែមានចំណុចខ្វះខាតដែលមិនទាន់អាចឆ្លើយតបបានគ្រប់ជ្រុងជ្រោយនោះទេ។ លោកជំទាវក៏បានផ្តល់ជាអនុសាសន៍ និងកិច្ចការចំពោះមុខត្រូវបន្តធ្វើក្នុងសិក្ខាសាលាដូចខាងក្រោមៈ

• ក្រសួង/ស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ទាំងអស់សុទ្ធតែមានយន្តការនិងនិតិវិធីក្នុងការអនុវត្តសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល និងបានរកឃើញនូវចំណុចខ្វះចន្លោះដែលត្រូវទាមទារឱ្យមានការជួបពិភាក្សាគ្នាបន្ថែមទៀតដើម្បីបង្កើនល្បឿនការផ្តល់ប័ណ្ណជូនស្រ្តីបម្រើការក្នុងសេវាកម្សាន្ត។

• សំណូមពរដល់ក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូគ្រប់លំដាក់ថ្នាក់ អនុវត្តនូវអនុសាសន៍របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** អោយទទួលបានជោគជ័យ។

• សំណូមពរដល់អាជ្ញាធរមូលដ្ឋាន ជួយសម្របសម្រួលស្រ្តីឱ្យមានឯកសារគ្រប់គ្រាន់ស្របតាមលក្ខណៈវិនិច្ឆ័យ ឯម្ចាស់សេវា មេការ ត្រូវតែមានបញ្ជីឈ្មោះស្រ្តីក្នុងហាងរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ និងដាក់លាក់ដើម្បីប្រគល់ជូនអាជ្ញាធរមូលដ្ឋាន ក្នុងការបន្តដំណើរការចុះឈ្មោះស្នើសុំប័ណ្ណ ម.ស.ស។

• សំណូមពរពង្រឹងនិងពង្រីកកិច្ចសហការឱ្យបានល្អប្រសើរ ចែករំលែកព័ត៌មានគ្នាជាប្រចាំនិងរៀបចំឱ្យបានការជួបជុំគ្នាឱ្យបានញឹកញាប់តាមតែអាចធ្វើទៅបាន។

• សំណូមពរក្នុងការពិចារណា លើការស្នើសុំពន្យារសុពលភាពនៃប័ណ្ណ ម.ស.ស និងប័ណ្ណក្រីក្រ រហូតដល់៣ឆ្នាំ សម្រាប់ការពិភាក្សាបន្ថែមលើយន្តការ ជាមួយបេឡាជាតិសន្តិសុខសង្គម។

លោកជំទាវ **ជូ ប៊ុនអេង** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោកលោកស្រីជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន សាលារាជធានីភ្នំពេញ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ អង្គការ-សមាគមជាតិ អន្តរជាតិទាំងអស់ដែលបានសហការគ្នាល្អក្នុងការអនុវត្តសេចក្តីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាលស្តីពីការផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល ដល់ជនបម្រើការនៅសេវាកម្សាន្ត និងសំណូមពរឱ្យនៅបន្តរួមគ្នាអនុវត្តផែនការយុទ្ធសាស្រ្តរាជរដ្ឋាភិបាល ក្នុងគោលនយោបាយជាតិបញ្ចកោណ ដំណាក់កាលទី១ បានជោគជ័យ។

លោកជំទាវ **ជូ ប៊ុនអេង** បានថ្លែងអំណរគុណដល់អង្គការសហប្រជាជាតិដើម្បីប្រជាជន (UNFPA) ប្រចាំប្រទេសកម្ពុជាដែល បានឧបត្ថម្ភគាំទ្រ ថវិកាសម្រាប់គម្រោង និងរៀបចំសិក្ខាលាលាដ៏មានសារៈសំខាន់នេះ និងជាដៃគូសហការយៈពេលវែង និងគួរឱ្យទុកចិត្តជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិលដូចជាសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ និងដៃគូរួមទាំងអ្នកពាក់ព័ន្ធដទៃទៀត។

លោកជំទាវ **ជូ ប៊ុនអេង** បានសំណូមពរដល់ម្ចាស់មូលនិធិទាំងអស់ មេត្តាបន្តផ្តល់នូវថវិកាទ្រទ្រង់គម្រោង ដ៏មានសារៈសំខាន់ទាំងឡាយ ដើម្បីសមាគមនារីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការកាត់បន្ថយជំងឺអេដស៍

លើកកម្ពស់សុខភាពបន្តពូជ និងសិទ្ធិទទួលបាននូវជម្រើសមធ្យោបាយពន្យារកំណើត និងសកម្មភាពជាច្រើនទៀតដើម្បីសុខភាពនិងវិបុលភាពសម្រាប់ស្ត្រីធ្វើការនៅក្នុងសេវាកម្សាន្ត។

**របៀបវារៈ**

| **កាលបរិច្ឆេទ** | **ប្រធានបទ** | **អ្នកសម្របសម្រួល** |
|---|---|---|
| ០៨:០០-០៨:៥០ | ភ្ញៀវកិត្តិយសអញ្ជើញដល់ | ក្រុមការងារសមាគមនារី |
| ០៨:៥០-០៩:០០ | គណៈអធិបតីអញ្ជើញដល់ | ក្រុមការងារសមាគមនារី |
| ០៩:០០-០៩:១០ | ប្រកាសហេតុ<br>គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា | លោកស្រី អៀង សុកក្រ្ត |
| ០៩:១០-០៩:១៥ | មតិស្វាគមន៍ ដោយអគ្គលេខាធិការសមាគមនារី | លោកជំទាវ មៀច សុធារី |
| ០៩:១៥-០៩:៣០ | ចំណាប់អារម្មណ៍ដោយនាយកប្រចាំប្រទេសរបស់មូលនិធិអង្គការសហប្រជាជាតិដើម្បីប្រជាជន(UNFPA) | Ms. Sandra Bernklau |
| ០៩:៣០-១០:១០ | បទបង្ហាញពី យន្តការ និងនិតិវិធីរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តរបបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់ស្ត្រីបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ | តំណាង៖<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- សាលារាជធានីភ្នំពេញ |
| ១០:១០-១០:៣០ | ចំណាប់អារម្មណ៍ និងការប្រកាសបើកសិក្ខាសាលា | សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ |
| ១០:៣០-១០:៥០ | ថតរូបអនុស្សាវរីយ៍ និងសម្រាកពិសារអាហារសម្រន់ | អ្នកចូលរួម |
| ១០:៥០-១០:៥៥ | សម្តេចកិត្តិសង្គហបណ្ឌិត<br>**ម៉ែន សំអន** ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ប្រធានសមាគមនារីអញ្ជើញត្រឡប់ទៅវិញ | |
| ១០:៥៥-១១:០៥ | បទបង្ហាញពី លទ្ធផលនៃការអង្កេតសិក្សាមុនអនុវត្តគម្រោងសុខភាពបន្តពូជនិងសិទ្ធិ | លោក ទិត្យ ច័ន្ទគ្រីស្នា - អ្នកសម្របសម្រួលគម្រោង |
| ១១:០៥-១១:២០ | បទបង្ហាញពី លទ្ធផលនៃការអនុវត្តគម្រោង និងដំណើរការនៃការសម្របសម្រួលស្ត្រីធ្វើការនៅក្នុងសេវាកម្សាន្តទៅទទួលប័ណ្ណមូលនិធិសមធម៌សុខាភិបាល | លោក ធន អាន -<br>ប្រធានកម្មវិធីសមាគមនារី |

| | | |
|---|---|---|
| ១១:២០-១២:០០ | វេទិកាសំណួរ និងចម្លើយ | អ្នកចូលរួម |
| ១២:០០-១៣:០០ | អាហារថ្ងៃត្រង់ | អ្នកចូលរួមទាំងអស់ |
| ១៣:៣០-១៥:៣០ | ពិភាក្សាក្រុមធំ ដើម្បីកំណត់បញ្ហាប្រឈម ដំណោះស្រាយ ក្នុងការជម្រុញនិងធ្វើឱ្យកាន់តែមានភាពងាយស្រួលដល់ស្ត្រី ធ្វើការនៅក្នុងសេវាកម្សាន្តទទួលបានប័ណ្ណមូលនិធិសមធម៌ សុខាភិបាល | អ្នកចូលរួម |
| ១៥:៣០-១៦:០០ | មតិបូកសរុប និងប្រកាសបិទសិក្ខាសាលា | លោកជំទាវ **ឌួ ម៉ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ |

## រូបភាពសកម្មភាពសិក្ខាសាលា



ថ្ងៃពុធ ៣ រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣

| | |
|---|---|
| រៀបចំដោយ | អនុម័តដោយ |
| អ្នកសម្របសម្រួលកម្មវិធី | ប្រធានកម្មវិធី |
| ទិត្យ ច័ន្ទគ្រីស្នា | ឆន អាន |